7/6

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍**

**សភាព្រហ្មទណ្ឌ**

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ : ១០០០

ចុះថ្ងៃទី ១៨_១២_០៦

**សាលដីកា**

លេខ : ៤០ "ខ"

ចុះថ្ងៃទី ០៣_០៤_០៨

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

..........

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ០៣-០៤-២០០៨ ដោយមានសមាសភាព ដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ:**

- **លោក** [redacted] ជាប្រធានក្រុមប្រឹក្សា
- **លោក** [redacted] ជាចៅក្រមប្រឹក្សា
- **លោក** [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

**លោក** [redacted]

**ក្រឡាបញ្ជី**

**កញ្ញា** [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខៈ ១០០០ ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០០៦ ដែលមាន:

**១- ជនជាប់ចោទឈ្មោះ** [redacted] **សុខខៃ ហៅ ជេម** ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ ទីលំនៅមុនពេលចាប់ខ្លួនផ្ទះលេខ[redacted]សង្កាត់បឹងសាឡាង ខណ្ឌទួលគោក ក្រុងភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] រ) ទោសពីមុនធ្លាប់ជាប់គុក ឃុំខ្លួនថ្ងៃទី១៤-០៧-២០០៥ បច្ចុប្បន្ននៅពន្ធនាគារព្រៃស ម១។

**២- ជនជាប់ចោទឈ្មោះ** [redacted] **ទីណា** ភេទប្រុស អាយុ ២៣ឆ្នាំ ជាតិខ្មែរ មុខរបររត់ម៉ូតូ ទីលំនៅមុនពេលចាប់ខ្លួន[redacted] ខណ្ឌទួលគោក ក្រុងភ្នំពេញ ប្រពន្ធឈ្មោះ [redacted] កូន១នាក់ ឪពុកឈ្មោះ[redacted](រ) ម្តាយឈ្មោះ [redacted](រ) ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី១៤-០៧-២០០៥ បច្ចុប្បន្ននៅពន្ធនាគារព្រៃស ម១។

**៣- ជនជាប់ចោទឈ្មោះ**[redacted]**សុជាត ហៅ**[redacted]**ស៊ីថា** ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ ទីលំនៅមុនពេលចាប់ខ្លួន[redacted] ខេត្តកំពង់ចាម ឪពុកឈ្មោះ[redacted](រ) ម្តាយឈ្មោះ [redacted]រ) នៅលីវ ចាប់ខ្លួនថ្ងៃទី ០៣-០២-២០០៥. ឃុំខ្លួនថ្ងៃទី ០៧-០២-២០០៥ បច្ចុប្បន្ននៅពន្ធនាគារព្រៃស ម១។

**៤- ជនជាប់ចោទឈ្មោះ** [redacted]**សុវណ្ណ ហៅ វ៉ាន់** ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីលំនៅមុនពេលចាប់ខ្លួនផ្ទះ[redacted] (គោកបញ្ចប់) សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោ[redacted](រ) បច្ចុប្បន្ននៅពន្ធនាគារព្រៃស ម១។



Scanned by CamScanner

**ត្រូវជាប់ចោទពីបទ:** ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០០៤ តាមមាត្រា ៦. ៥៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- តាមពាក្យបណ្តឹងឧទ្ធរណ៍លេខ ៤៦៧ ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted]**សុខខៃ** និងបណ្តឹងឧទ្ធរណ៍លេខ ៣៩២ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted]**ណា** ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៣១ ច ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០០៦ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចទាំងមូល នៃសេចក្តីសម្រេច ។

**ដំណើររឿងមានដូចតទៅ:**

នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៤ វេលាម៉ោង១៣និង៣០នាទី មានករណីប្លន់ (ម៉ូតូ) ម៉ាកសេ១២៥ ពណ៌ខ្មៅ ស៊េរី២០០៣ បិតតែមស៊េរី២០០៤ នៅមុំវត្តដំបូកខ្ពស់ ផ្លូវលំ ក្រុម១០ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ ក្រុងភ្នំពេញ ជនរងគ្រោះក្នុងករណីប្លន់នេះមានឈ្មោះ [redacted] **ស្រីពៅ** ភេទស្រី អាយុ ៣១ឆ្នាំ រស់នៅផ្ទះលេខ៨ ផ្លូវ៤៨៤ សង្កាត់បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ នៅពេលដែលជនរងគ្រោះជូនកូនទៅសាលាហើយ ហើយត្រឡប់មកផ្ទះបងដែលស្នាក់នៅបណ្តោះអាសន្ន ដោយផ្ទះខ្លួននឹងធ្វើពុំទាន់រួច នៅក្បែរកន្លែងកើតហេតុ ក៏ត្រូវជនល្មើសមានគ្នា ៤នាក់ មានឈ្មោះ [redacted] **សុខខៃ**, ឈ្មោះ[redacted]**ទីណា**, ឈ្មោះ[redacted] **សុជាត** និងឈ្មោះ[redacted]**សុវណ្ណ** ដោយជិះម៉ូតូ ២គ្រឿង មួយគ្រឿងម៉ាកវ៉ានឌីឡាវ ពណ៌ក្រហម និងមួយគ្រឿងទៀតម៉ាកសង់ ពណ៌ខ្មៅ មានកាំភ្លើងមួយដើមពុំស្គាល់ម៉ាក ប្លន់កៀរយកម៉ូតូតែម្តង ។ ពេលពួកវាយកម៉ូតូបាន ពួកវាក៏ជិះម៉ូតូវិលត្រឡប់ឡើងទៅលើផ្លូវលេខ ២៧១ វិញ តែពុំបានឃើញបត់ស្តាំ ឬបត់ឆ្វេងឡើយ ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ១៣១ ច ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០០៦ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ផ្តន្ទាទោសឈ្មោះ :

- [redacted]**សុខខៃ ហៅ ជេម** ភេទប្រុស អាយុ ២៥ឆ្នាំ
- [redacted]**សុជាត ហៅ**[redacted] **ស៊ីថា** ភេទប្រុស អាយុ ២៧ឆ្នាំ

ដាក់ពន្ធនាគារក្នុងមួយម្នាក់ៗ កំណត់ ៦ឆ្នាំ (ប្រាំមួយឆ្នាំ) គិតពីថ្ងៃអនុវត្តទោសតាមអំណាចសាលក្រមពីមុន១ចប់ ពីបទ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិក្បាលទំនប់ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៤ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២- ផ្តន្ទាទោសឈ្មោះ [redacted] **ទីណា** ភេទប្រុស អាយុ ២៣ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៦ឆ្នាំ (ប្រាំមួយឆ្នាំ) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៥ ពីបទ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិក្បាលទំនប់ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០០៤ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣- ផ្តន្ទាទោសឈ្មោះ [redacted]**សុវណ្ណ ហៅ វ៉ាន់** ភេទប្រុស អាយុ ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៦ឆ្នាំ (ប្រាំមួយឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបាន ពីបទ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិក្បាលទំនប់ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ



Scanned by CamScanner

រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០០៤ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៤- បង្គាប់ឱ្យឈ្មោះ [redacted] សុខខៃ ហៅ ជេម ឈ្មោ[redacted] សុជាត ហៅ[redacted] ស៊ីថា ឈ្មោះ [redacted] ទីណា និងឈ្មោះ [redacted] សុវណ្ណ ហៅ វ៉ាន់ រួមគ្នាសងសំណងជូសជុលការខូចខាតចំនួន ៩០០ដុល្លា ( ប្រាំបួនរយដុល្លាអាមេរិក) ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីពៅ ផ្ទះលេខ៨ ក្រុម២៧ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។ ក្នុងករណីរឹងរូសពុំព្រមសងត្រូវដាក់គុកបង្ខំដល់រូបកាយ ដើម្បីទារប្រាក់ធនទណ្ឌនេះតាមមាត្រា ៧ និង ១០ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៥- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុខខៃ ឈ្មោះ [redacted]ទីណា និងមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សុជាត ហៅ [redacted] ស៊ីថា ឈ្មោ[redacted]សុវណ្ណ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៤៦៧ ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] សុខហៃ និងបណ្តឹងឧទ្ធរណ៍លេខ ៣៩២ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០០៦ របស់ឈ្មោ[redacted]ទីណា ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៣១ ច ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០០៦ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចទាំងមូល នៃសេចក្តីសម្រេច ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍ ។

- បានឃើញរបាយការណ៍រឿងចុះថ្ងៃទី១១៩ ខែធ្នូ ឆ្នាំ២០០៧ របស់ចៅក្រមសាលាឧទ្ធរណ៍ ។

**<u>ទាខេលសវចាតារ</u>**

ចៅក្រមអានរបាយការណ៍រឿង

ជនជាប់ចោទឈ្មោះ [redacted] សុខខៃ ឆ្លើយថា : ខ្លួនមានរឿងច្រើនពេក ខ្លួនប្តឹងសុំឱ្យលោកប្រធានមេត្តាបន្ធូរបន្ថយទោសឱ្យខ្លួនផង ។ នៅថ្ងៃ ០៩-០៧-២០០៤ ខ្លួនបានធ្វើតែពីរនា[redacted]សុជាត ទេ ចំពោះ[redacted] សុវណ្ណ ខ្លួនមិនដែលស្គាល់ទេ ។ កាំភ្លើង K59 មិនមែនជាកាំភ្លើងរបស់[redacted] សុវណ្ណ ទេ ចំពោះចម្លើយ[redacted]សុវណ្ណ ដកកាំ ភ្លើងនោះមិនមែនទេ ព្រោះខ្លួន និង [redacted] សុជាត មានកាំភ្លើងម្នាក់មួយហើយ ។ ថ្ងៃដែលខ្លួនប្រព្រឹត្ត គឺខ្លួន និង[redacted]សុជាត ឯ [redacted] ទីណា មិនបានប្រព្រឹត្តទេ ។ ខ្លួនមិនដែលស្គាល់[redacted] សុវណ្ណ ទេ ។ ខ្លួនត្រូវចាប់ខ្លួនថ្ងៃទី ០៥-០៧-២០០៥ ។

ជនជាប់ចោទឈ្មោ[redacted]ណា ឆ្លើយថា : ខ្លួនប្តឹងឧទ្ធរណ៍ ព្រោះតុលាការសម្រេចផ្តន្ទាទោសខ្លួន ដោយខ្លួនមិនបានប្រព្រឹត្ត ។ ខ្លួនមិនមែនជាបងប្អូ[redacted]សុជាត ទេ ។ ខ្លួនអត់ស្គាល[redacted] សុវណ្ណ ទេ ខ្លួនស្គាល់តែ[redacted] សុខខៃ ។ ខ្លួនត្រូវចាប់ខ្លួនថ្ងៃទី ០៧-០៧-២០០៥ ខ្លួនមិនដែលមានទំនាស់ជាមួយសមត្ថកិច្ចទេ ។

ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ឆ្លើយថា : ខ្លួនមិនបានចូលរួមទេ ហើយខ្លួនក៏មិនដែលជិះម៉ូតូសង់ ហើយកាំភ្លើង K59 ខ្លួនមិនដែលមានទេ ខ្លួនមានតែម៉ូតូអាសង់កូរ៉េ សម្រាប់រត់ឌុប ខ្លួនមិនបានប្រព្រឹត្តទេ ។ ថ្ងៃចាប់ខ្លួន ០៥-០៨-២០០៥ ហើយខ្លួនមិនដែលទៅវត្តជំបូកខ្លស់ទេ ។



Scanned by CamScanner

7/3

## សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្នុងរឿងនេះ ជនជាប់ចោទ [redacted] សុខខៃ បានសារភាពថា នៅថ្ងៃទី ០៩-០៧-២០០៤ ខ្លួនមានបក្សពួក ០៤នាក់ បានប្លន់ទៅតំបន់តំបូកខ្ពស់ ហើយចម្លើយនេះមានភាពស៊ីសង្វាក់គ្នាទៅនឹងចម្លើយជនរងគ្រោះ ។

យល់ថាមានពិរុទ្ធភាព គ្រប់គ្រាន់ លើជនជាប់ចោទ ពីបទប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភ្នំពេញ កាលពីថ្ងៃទី ០៩-០៧-២០០៤ តាមមាត្រា ៦. ៩៤ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោស និងច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

យល់ថាសំអាងហេតុក្នុងសាលក្រមលេខ ១៣១ ច ចុះថ្ងៃទី ២៩-០៨-២០០៦ របស់តុលាការក្រុងភ្នំពេញ មានលក្ខណៈត្រឹមត្រូវ គប្បីតម្កល់ទុកជាបានការ ។

## សេចក្ដីសន្និដ្ឋានរបស់មេធាវី

រឿង [redacted] សុខខៃ មានសំណុំរឿង ១៣រឿង ហើយការនាំខ្លួនជនល្មើសមានជាង ៣០នាក់ ហើយពិតជាមានការធ្វើទណ្ឌកម្មពិតប្រាកដទៅលើជនជាប់ចោទ ហើយមូលហេតុតែការចាប់ខ្លួននេះ គឺមានការភ័ន្តច្រឡំទៅលើកូនក្ដីខ្ញុំ [redacted] សុវណ្ណ ព្រោះការជំនុំជម្រះ និងការចាប់ខ្លួនមិនស៊ីសង្វាក់គ្នា ហើយកូនក្ដីខ្ញុំ [redacted] សុខខៃ បានសារភាពថា ក្នុងការប្រព្រឹត្តគឺគាត់មិនដែលមានគ្នាលើពី ០៣នាក់ទេ ហើយគាត់បានបញ្ជាក់ថាគាត់បានប្រព្រឹត្តក្នុងសំណុំរឿងនេះ មានគ្នាតែ ០២នាក់ ហើយគាត់ឆ្លើយថា គាត់មិនបានស្គាល់ [redacted] សុវណ្ណ និង ឡី សុជាត ទេ សូមធ្វើការលើកលែងចោទប្រកាន់ដល់កូនក្ដីខ្ញុំ [redacted] សុវណ្ណ និង [redacted] សុជាត និងសូមធ្វើការបន្ធូរបន្ថយទោសដល់ [redacted] សុខខៃ និង [redacted] ណា ។

- ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវី
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា:

១- បណ្ដឹងឧទ្ធរណ៍លេខ ៣៩២ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] ទីណា, បណ្ដឹងឧទ្ធរណ៍លេខ ៤៦៧ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] សុខខៃ និងបណ្ដឹងឧទ្ធរណ៍លេខ ៣២០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៧ របស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ធ្វើឡើងនៅក្នុងកំណត់ច្បាប់ ។

២- តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សុខខៃ នៅសវនាការសាលាឧទ្ធរណ៍ថា កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៤ វេលាម៉ោង១២ ខ្លួនបានធ្វើសកម្មភាពប្លន់ម៉ូតូនៅចំណុចផ្លូវលំចូលវត្តជ័យតំបូកខ្ពស់មែន តែក្នុងការធ្វើសកម្មភាពនាពេលនោះ ខ្លួនធ្វើតែពីរនាក់ [redacted] សុជាត ទេ ចំណែកឈ្មោះ [redacted] ទីណា និងឈ្មោះ [redacted] សុវណ្ណ មិនចូលរួមជាមួយខ្លួនទេ ហើយខ្លួនក៏មិនដែលស្គាល់អ្នកទាំងពីរនាក់នេះដែរ ។ រាល់សកម្មភាពប្លន់របស់ខ្លួន គ្មានពាក់ព័ន្ធនឹងឈ្មោះ [redacted] ទីណា និង [redacted] សុវណ្ណ ទេ ។

តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ទីណា ថា កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៤ ខ្លួនមិនបានចូលរួមប្លន់ជាមួយឈ្មោះ [redacted] សុខខៃ ទេ ខ្លួនស្គាល់ ជួន សុខខៃ យូរហើយ ដោយផ្ទះនៅជិតគ្នា ឯឈ្មោះ [redacted] សុវណ្ណ ខ្លួនមិនដែលស្គាល់ទេ ។



Scanned by CamScanner

តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ថា ខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] សុខខៃ និង [redacted] ទីណា ទេ ហើយ កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៤ ខ្លួនមិនបានធ្វើសកម្មភាពប្លន់ជាមួយឈ្មោះ [redacted] សុខខៃ ទេ ហើយក៏មិនបានទិញម៉ូតូពីឈ្មោះ [redacted] សុខខៃ ដែរ ។

ដូច្នេះអាចកំណត់បានថាឈ្មោះ [redacted] ទីណា និង [redacted] សុវណ្ណ ពុំបានចូលរួមធ្វើសកម្មភាពប្លន់កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៤ ជាមួយជនជាប់ចោទឈ្មោះ [redacted] សុខខៃ ទេ ហើយឈ្មោះ [redacted] សុវណ្ណ ក៏មិនបានទទួលទិញម៉ូតូពីឈ្មោះ [redacted] សុខខៃ ដែរ ។

៣- មានពិរុទ្ធលើជនជាប់ចោទឈ្មោះ [redacted] សុខខៃ ពីបទ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិក្បាលទំនប់ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ កាលពីថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០០៤ បទល្មើសមានចែង និងឱ្យផ្ដន្ទាទោស តាមមាត្រា ៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៤- គ្មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ទីណា និង [redacted] សុវណ្ណ ពីបទ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិក្បាលទំនប់ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ កាលពីថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០០៤ បទល្មើសមានចែង និងឱ្យផ្ដន្ទាទោស តាមមាត្រា ៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដូចការចោទប្រកាន់របស់អយ្យការអមតុលាការក្រុងភ្នំពេញ ដូច្នេះ គួរឱ្យឈ្មោះ [redacted] ទីណា និង [redacted] សុវណ្ណ រួចផុតពីបទចោទ ។

៥- សាលក្រមព្រហ្មទណ្ឌលេខ ១៣១ ច ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០០៦ របស់សាលាដំបូងក្រុងភ្នំពេញ សម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ វៀរលែងតែចំណុចទី ២ និងទី ៣ គួរបដិសេធចោល ហើយសម្រេចឡើងវិញ ដូចយល់ឃើញខាងលើ និងគួរលុបឈ្មោះ [redacted] ណា និង [redacted] សុវណ្ណ ចេញពីចំណុចទី ៤ ក្រៅពីនេះទុកនៅដដែល ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១-ក/ ទទួលបណ្ដឹងឧទ្ធរណ៍លេខ ៤៦៧ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៦ របស់ជនជាប់ចោទឈ្មោះ **ជួន សុខហៃ** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់.

ខ/ ទទួលបណ្ដឹងឧទ្ធរណ៍លេខ ៣៩២ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៦ របស់ជនជាប់ចោទឈ្មោះ **ឌី ទីណា** និងបណ្ដឹងឧទ្ធរណ៍លេខ ៣២០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៧ របស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៣១ ច ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០០៦ របស់សាលាដំបូងក្រុងភ្នំពេញ ទុកជាបានការ វៀរលែងតែចំណុចទី ២ និងទី ៣ ត្រូវបដិសេធ ហើយសម្រេចឡើងវិញថា ឱ្យឈ្មោះ [redacted] ទីណា ភេទប្រុស អាយុ ២៣ឆ្នាំ និងឈ្មោះ [redacted] សុវណ្ណ ភេទប្រុស អាយុ ២៥ឆ្នាំ រួចផុតពីបទចោទប្រកាន់ ពីបទ ប្លន់ និងប្រើប្រាស់អាវុធ ខុសច្បាប់ ប្រព្រឹត្តនៅភូមិក្បាលទំនប់ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ កាលពីថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០០៤ តាមមាត្រា ៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ៥៤ នៃច្បាប់ព្រហ្មទណ្ឌ



Scanned by CamScanner

អន្តរកាល និងឱ្យលុបឈ្មោ[redacted]ណា និ[redacted] សុវណ្ណ ចេញពីចំណុចទី ៤ ស្តីពីសំណង ក្រៅពីនេះរក្សាទុកនៅដដែល ។

៣- បង្គាប់ឱ្យដោះលែងឈ្មោះ [redacted] ទីណា និងឈ្មោះ [redacted] សុវណ្ណ ចេញពីមន្ទីរឃុំឃាំងភ្លាម បើឈ្មោះទាំងពីរនេះ មិនត្រូវបានឃុំខ្លួនពីបទអ្វីផ្សេងទៀតទេ ។

៤- បង្គាប់ឱ្យបន្តការឃុំខ្លួនជនជាប់ចោទឈ្មោ[redacted] សុខខៃ ។

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវសាទុក្ខតាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា: | ហត្ថលេខា: | ហត្ថលេខា: |
| [redacted] | [redacted] | [redacted] |

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៩

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

174



Scanned by CamScanner